# សេចក្តីសង្ខេបការស្រាវជ្រាវស្តីពីអនុសាសន៍នៃការអនុវត្តល្អបំផុតសម្រាប់កិច្ចការពារ និងការគាំទ្រសាក្សីនៅចំពោះមុខ អ.វ.ត.ក

## ១.គោលបំណង

ការស្រាវជ្រាវនេះមានគោលបំណង ៖

ក. វាយតម្លៃសេវាការពារ និងសេវាគាំទ្រដែលផ្តល់ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

ខ. កំណត់រកប្រព័ន្ធ និងនីតិវិធីដែលរួមចំណែកជួយឱ្យសាក្សីអាចផ្តល់សក្ខីកម្មក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិ ដោយមិនប្រឈមនឹងផលវិបាកអវិជ្ជមានណាមួយ។

## ២.វិធីសាស្ត្រ

### ២.១ ការពិចារណាផ្នែកវិធីសាស្ត្រ

ក្នុងការរៀបចំការស្រាវជ្រាវ មានការពិចារណាលើចំណុចសំខាន់ៗដូចខាងក្រោម ៖

- ក្របខ័ណ្ឌពេលវេលាខ្លីសម្រាប់ការបញ្ចប់គម្រោង
- ភាពចាំបាច់ក្នុងការសម្ភាសសាក្សីឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ពោលគឺសាក្សីដែលបានផ្តល់សក្ខីកម្មនៅ អ.វ.ត.ក
- ជំនាញ និងបទពិសោធន៍ចម្រុះរបស់បុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលជាអ្នកដែលត្រូវធ្វើបទសម្ភាសន៍ និង
- ភាពចាំបាច់ក្នុងការគ្របដណ្តប់លើគ្រប់ទិដ្ឋភាពទាំងអស់នៃបទពិសោធន៍របស់សាក្សីជាមួយនឹង អ.វ.ត.ក និងការរក្សាតុល្យភាពរវាងភាពចាំបាច់នេះ និងភាពចាំបាច់ក្នុងការរក្សាឱ្យបទសម្ភាសន៍ខ្លីល្មម។

### ២.២ កាលវិភាគសម្ភាសន៍

សាក្សីត្រូវបានសួរសំណួរស្តីពីបទពិសោធន៍របស់ពួកគេពាក់ព័ន្ធនឹងចំណុចខាងក្រោម ៖

- ទំនាក់ទំនងដំបូងរបស់ពួកគេជាមួយ អ.វ.ត.ក (ឧ. ភាពថប់អារម្មណ៍នៅពេលធ្វើទំនាក់ទំនងដំបូង)
- កត្តាជំរុញឱ្យពួកគេផ្តល់សក្ខីកម្ម
- ទំនាក់ទំនងមុនពេលផ្តល់សក្ខីកម្មជាមួយ អ.វ.ត.ក (ឧ. ការផ្តល់ចម្លើយដល់អ្នកស៊ើបអង្កេត)
- ការរៀបចំដែលពួកគេទទួលបានសម្រាប់ការផ្តល់សក្ខីកម្ម

- សេវារបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងពេលផ្តល់សក្ខីកម្ម (ឧ. កន្លែងស្នាក់នៅ សន្តិសុខ ថ្នាំសង្កូវ)
- បទពិសោធន៍របស់សាក្សីក្នុងការផ្តល់សក្ខីកម្ម (អារម្មណ៍នៅមុនពេល ក្នុងពេល និងក្រោយពេលផ្តល់សក្ខីកម្ម)
- សេវាដែលផ្តល់ដោយអង្គភាពគាំពារសាក្សី និងជនរងគ្រោះក្រោយការផ្តល់សក្ខីកម្ម (ឧ. សន្តិសុខ ការរក្សាទំនាក់ទំនងជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ)
- ថាតើគ្រួសាររបស់ពួកគាត់ទទួលរងផលប៉ះពាល់ដូចម្តេច ដោយសារពួកគាត់ធ្វើជាសាក្សីនៅ អ.វ.ត.ក
- ថាតើសហគមន៍របស់ពួកគាត់មានប្រតិកម្មបែបណាចំពោះពួកគាត់ដែលធ្វើជាសាក្សី ប្រសិនបើសហគមន៍បានដឹងពីដំណឹងនេះ
- ទស្សនៈរបស់សាក្សីចំពោះការងាររបស់ អ.វ.ត.ក (ឧ. គោលបំណងរបស់ អ.វ.ត.ក ទំនុកចិត្តរបស់ អ.វ.ត.ក ក្នុងការសម្រេចបានគោលបំណងរបស់ខ្លួន) និង
- ស្ថានភាពបច្ចុប្បន្នរបស់សាក្សី (ឧ. កង្វល់ និងសុខុមាលភាពផ្លូវចិត្តរបស់ពួកគាត់នាពេលបច្ចុប្បន្ន)

## ៣.អនុសាសន៍ស្តីពីការអនុវត្តល្អបំផុត

អនុសាសន៍ដែលលើកឡើងនេះ ផ្អែកទាំងស្រុងលើការវាយតម្លៃរបស់សាក្សីចំពោះបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់។ ទោះបីជានេះជាវិធានការដែលមានសុពលភាពក្នុងការធានាប្រសិទ្ធភាពនៃកិច្ចការពារ និងការគាំទ្រដែលផ្តល់ជូនក៏ដោយ ក៏ការបញ្ចូលទស្សនៈរបស់បុគ្គលិក អ.វ.ត.ក ដែលធ្វើការជាមួយសាក្សី (ជាពិសេសបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក៏ដូចជាបុគ្គលិកផ្នែកច្បាប់) នឹងបំពេញបន្ថែមដល់ការយល់ដឹងនេះ។